**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៦០៦ ព.ណ.ផ.ស.ប

ថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន សាធារណៈជនទាំងអស់មេត្តាជ្រាបថា នៅក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះតម្លៃប្រេងឥន្ទនៈនៅលើទីផ្សារអន្តរជាតិមានការកើនឡើង។ ប៉ុន្តែ ទោះបីមានការកើនឡើងតម្លៃប្រេងឥន្ទនៈក្តី ក៏តម្លៃលក់រាយប្រេងឥន្ទនៈនៅកម្ពុជាមានសមាមាត្រកើនឡើងតិចជាងសមាមាត្រនៃការកើនឡើងតម្លៃប្រេងឥន្ទនៈនៅលើទីផ្សារអន្តរជាតិ។ ជាក់ស្តែងតម្លៃលក់រាយនៅកម្ពុជាប្រេងសាំងធម្មតា (EA92) នៅក្នុងដើមខែមេសា ឆ្នាំ ២០១៦ មានតម្លៃ០.៨០ដុល្លារ ក្នុង១លីត្រ ប៉ុន្តែនៅក្នុងចុងខែមេសា ឆ្នាំ២០១៨ មានតម្លៃ១.០២ ដុល្លារ ក្នុង១លីត្រ កើន ២៧% នៅពេលដែលតម្លៃប្រេងឥន្ទនៈនៅលើទីផ្សារអន្តរជាតិកើនឡើង៦៣% ក្នុងរយៈពេលដូចគ្នា (ដូចមានតារាងប្រៀបធៀបតម្លៃជូនភ្ជាប់)។

សមាមាត្រនៃតម្លៃលក់រាយប្រេងឥន្ទនៈនៅកម្ពុជាមានការកើនឡើងតិចជាងសមាមាត្រ នៃការកើនឡើងតម្លៃប្រេងឥន្ទនៈ នៅលើទីផ្សារអន្តរជាតិគឺដោយសាររូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ទនៈនៅកម្ពុជាត្រូវបានកំណត់ដោយអន្តរក្រសួងរួចមកហើយ ដែលមានក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល។

សូមជម្រាបជូនថា ប្រេងឥន្ទនៈស្ទើរតែទាំងអស់ ដែលដាក់លក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺមានប្រភពដើមនាំចូលមកពីប្រទេសសិង្ហបុរីដូចគ្នា។

យើងអាចមើលឃើញតម្លៃប្រេងឥន្ទនៈខាងលើនេះជារៀងរាល់ពេលតាមរយៈ Facebook: www.facebook.com/moc.gov.kh និងគេហទំព័រដែលមានអាសយដ្ឋាន www.moc.gov.kh របស់ក្រសួងពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន ដោយមេត្រីភាព។

**តារាងប្រៀបធៀបតម្លៃលក់រាយប្រេងឥន្ទនៈនៅកម្ពុជាធៀបនឹងតម្លៃប្រេងឥន្ទនៈនៅលើទីផ្សារអន្តរជាតិ ពីដើមខែមេសា ឆ្នាំ២០១៦ ដល់ចុងខែមេសា ឆ្នាំ២០១៨**

| Date | EA 95 | | EA 92 | | DO 0.05% | |
|---|---|---|---|---|---|---|
| | (USD/Barrel) | (USD/Litre) | (USD/Barrel) | (USD/Litre) | (USD/Barrel) | (USD/Litre) |
| 1-Apr-16 | 52.45 | 0.82 | 49.62 | 0.80 | 44.92 | 0.69 |
| 3-Apr-17 | 67.19 | 0.91 | 64.19 | 0.9 | 63.34 | 0.82 |
| 2-Apr-18 | 80.84 | 1.06 | 78 | 0.99 | 83.45 | 0.94 |
| 30-Apr-18 | 83.82 | 1.09 | 80.9 | 1.02 | 86.58 | 0.97 |


ក្រាហ្វិកបម្រែបម្រួលតម្លៃ MOPS ពីដើមខែមេសា ឆ្នាំ២០១៦ ដល់ចុងខែមេសា ឆ្នាំ២០១៨
$90.00
$85.00
$80.00
$75.00
$70.00
$65.00
$60.00
$55.00
$50.00
$45.00
$40.00
1-Apr-16
3-Apr-17
2-Apr-18
30-Apr-18
52.45
49.62
44.92
67.19
64.19
63.34
83.45
80.84
78
86.58
83.82
80.9
(USD/Barrel)
(USD/Barrel)
(USD/Barrel)